EQUATOR INITIATIVE

UNDP

*Empowered lives.*
*Resilient nations.*




# គណៈកម្មការសហគមន៍ តំបន់ការពារធម្មជាតិ ត្មាតប៉ើយ ធឿនក្រសាំង

## នៅកម្ពុជា

## ករណីសិក្សានៃកិច្ចផ្តួចផ្តើមអេក្វាទ័រ

ដំណោះស្រាយអភវឌ្ឍន៍ដោយចីរភាពនៅមូលដ្ឋាន ដើម្បីប្រជាពលរដ្ឋ ធម្មជាត និងសហគមន៍រឹងមាំ

# កម្រងករណីសិក្សាអំពីកិច្ចផ្តួចផ្តើមអេក្វាទ័ររបស់យូអិនឌីភី

សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចនៅទូទាំងពិភពលោក កំពុងជម្រុញដំណោះស្រាយអភិវឌ្ឍន៍ ដោយ ចីរភាពតាមបែបច្នៃប្រឌិតដែលជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ និងធម្មជាតិ។ មានឯកសារបោះពុម្ពផ្សាយ ឬករណី សិក្សាតិចតួចណាស់ដែលបង្ហាញថាតើកិច្ចផ្តួចផ្តើមនេះវិវត្តរបៀបណា មានវិសាលភាពឥទ្ធិពលដូចម្តេច ឬថាតើវាប្រែប្រួលបែបណាខ្លះ។ មានករណីសិក្សាមួយចំនួនតូចដែលរឿងរ៉ាវទាំងនេះ ដោយមានអ្នកអនុវត្តន៍សហគមន៍ដោយខ្លួនឯងផ្ទាល់ ជាអ្នកនិទានប្រាប់។

ដើម្បីរម្លឹកខួបទី ១០របស់ខ្លួន កិច្ចផ្តួចផ្តើមអេក្វាទ័រ មានគោលដៅបំពេញភាពខ្វះចន្លោះនេះ។ករណីសិក្សាដូចខាងក្រោមនេះ ស្ថិតក្នុងចំណោមករណីដែលមានចំនួនកាន់តែច្រើនឡើង ដែលរៀបរាប់ពិស្តារអំពីកិច្ចការរបស់ជ័យលាភី អេក្វាទ័រ ពោលគឺជារឿងអំពីទម្លាប់ល្អដែលបានទទួលការពិនិត្យ និងផ្ទៀងផ្ទាត់ពីសំណាក់ក្រុមអ្នកជំនាញ ក្នុងកិច្ចការ អភិរក្សបរិស្ថាននិងការចិញ្ចឹមជីវិតដោយចីរភាពនៅក្នុងសហគមន៍។ ករណីសិក្សាទាំងនេះមានបំណងញ៉ាំងឲ្យមានការពិភាក្សាអំពីគោលនយោបាយ ដែលចាំបាច់សម្រាប់ពង្រីកជោគជ័យនៅមូលដ្ឋាន ដើម្បីកែលម្អចំណេះដឹងសកលជាមូលដ្ឋានអំពីដំណោះស្រាយសម្រាប់បរិស្ថាន និងការអភិវឌ្ឍនៅមូលដ្ឋាន និងដើម្បីផ្តល់ជាគំរូសម្រាប់ការចម្លងទៅអនុវត្ត នៅកន្លែងដទៃ។ ដើម្បីស្វែងយល់ពីករណីសិក្សាទាំងនេះ សូមយោងទៅអត្ថបទ *The Power of Local Action: Lessons from 10 Years of the Equator Prize* ដែលជាកម្រងមេរៀន និងការណែនាំគោលនយោបាយដែលផ្អែកលើឯកសារនានាអំពីករណីទាំងនេះ។



## ក្រុមនិពន្ធកែសម្រួល

និពន្ធនាយក៖ Joseph Corcoran
អ្នកគ្រប់គ្រងការនិពន្ធ៖ Oliver Hughes
អ្នកចូលរួមកែសម្រួល៖ Dearbhla Keegan, Matthew Konsa, Erin Lewis, Whitney Wilding

## អ្នករួមចំណែកក្នុងការនិពន្ធ

Edayatu Abieodun Lamptey, Erin Atwell, Toni Blackman, Jonathan Clay, Joseph Corcoran, Larissa Currado, Sarah Gordon, Oliver Hughes, Wen-Juan Jiang, Sonal Kanabar, Dearbhla Keegan, Matthew Konsa, Rachael Lader, Patrick Lee, Erin Lewis, Jona Liebl, Mengning Ma, Mary McGraw, Gabriele Orlandi, Brandon Payne, Juliana Quaresma, Peter Schecter, Martin Sommerschuh, Whitney Wilding, Luna Wu

## រចនាបថដោយ

Oliver Hughes, Dearbhla Keegan, Matthew Konsa, Amy Korngiebel, Kimberly Koserowski, Erin Lewis, John Mulqueen, Lorena de la Parra, Brandon Payne, Mariajosé Satizábal G.


## សេចក្តីថ្លែងអំណរគុណ

កិច្ចផ្តួចផ្តើមអេក្វាទ័រ សូមថ្លែងអំណរគុណដោយស្មោះចំពោះ គណៈកម្មការតំបន់ការពារធម្មជាតិសហគមន៍ត្នោតបឿយ និងជាពិសេស ការណែនាំ និងយោបល់ដែលបានពីលោក Ashish John និង Hugo Raine។ រូបថតទាំងអស់បានមកពី Eleanor Briggs, Ashish John, Sok Sony, និង Rours Vann ។ ផែនទីបានមកពី CIA World Factbook និង Wikipedia។


## គួរសរសេរសេចក្តីយោងដូចតទៅ

United Nations Development Programme. 2012. *Monks Community Forest, Cambodia*. Equator Initiative Case Study Series. New York, NY.

# គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្នោតប៉ើយ ធឿនក្រសាំង នៅកម្ពុជា

## សេចក្តីសង្ខេបគម្រោង

ភូមិត្នោតប៉ើយមានប្រជាជនរស់នៅចំនួន ២៣៦ គ្រួសារ ដែលក្នុងចំណោមនោះ មានគ្រួសារខ្លះជាសមាជិកជនជាតិដើមភាគតិចគួយ ហើយភូមិនេះស្ថិតក្នុងខេត្តព្រះវិហារ នៃតំបន់ខ្ពង់រាបភាគខាងជើងប្រទេសកម្ពុជា។ តំបន់នេះជាទីជម្រករស់នៅបន្តពូជសត្វត្រយ៉ងយក្ស និងត្រយ៉ងមានចំកំកស ក្នុងចំនួនច្រើនជាងគេបង្អស់លើពិភពលោក ហើយសត្វស្លាបទាំងពីរប្រភេទនេះស្ថិតក្នុងចំណោមពពួកសត្វកំពុងរងការគម្រាមកំហែងខ្លាំង។ ជាសរុប តំបន់នេះផ្តល់ការទ្រទ្រង់ដល់ប្រភេទសត្វ ៥០ប្រភេទ ដែលត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ អន្តរជាតិអភិរក្សសត្វព្រៃ IUCN។ សម្រាប់ភាគច្រើននៃសត្វទាំងនេះ វាលទំនាបខាងជើងជាជម្រកចុងក្រោយ ដែលធ្វើឲ្យ តំបន់ដែនដីនេះជាចំណុចផ្តោតយកចិត្តទុកដាក់យ៉ាងសំខាន់មួយសម្រាប់ធ្វើអន្តរាគមន៍កិច្ចអភិរក្ស។ វិធីមួយក្នុងកិច្ចអភិរក្សនេះគឺប្រើចំណូលពីទេសចរណ៍ធម្មជាតិ ធ្វើជា"រង្វាន់" ឲ្យដល់សមាជិកសហគមន៍ត្នោតប៉ើយ ធឿន ក្រសាំង ក្នុងការជួយអភិរក្សសត្វស្លាបកម្រទាំងនេះ។ ក្នុងន័យនេះ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្នោតប៉ើយធឿនក្រសាំងបាន សហការជាមួយអង្គការអភិរក្សសត្វព្រៃ Wildlife Conservation Society ដើម្បីដាក់ចេញជាផែនការ ត្រួតពិនិត្យជាលក្ខណៈសហគមន៍មួយ ដែលក្នុងនោះអ្នកស្រុកទទួលបានកម្រៃជាថ្នូរទៅនឹងការរាយការណ៍ និងត្រួតពិនិត្យ តាមដានសំបុកសត្វ ជំនួសឲ្យការយកស៊ុតសត្វទាំងនោះទៅលក់នៅទីផ្សារងងឹតនៅតាមព្រំដែនថៃ-ឡាវវិញ។

## ព័ត៌មានគោល

ជ័យលាភីរង្វាន់អេក្វាទ័រៈ ឆ្នាំ ២០០៨

ទីកន្លែងៈ ខេត្តព្រះវិហារ

អ្នកទទួលផលៈ ២៣៦ គ្រួសារ

ជីវៈចម្រុះៈ តំបន់ជម្រកសត្វព្រៃគូលេន ព្រហ្មទេព



## មាតិកា


| | |
|---|---|
| សាវតារ និងបរិបទ | 4 |
| សកម្មភាពសំខាន់ៗ និងការច្នៃប្រឌិត | 6 |
| ឥទ្ធិពលលើជីវៈចម្រុះ | 8 |
| ឥទ្ធិពលលើសេដ្ឋកិច្ចសង្គម | 9 |
| ឥទ្ធិពលលើគោលនយោបាយ | 10 |
| និរន្តរភាព | 11 |
| ការចម្លងទៅអនុវត្តនៅកន្លែងផ្សេង | 11 |
| ដៃគូនានា | 12 |

# សាវតារ និងបរិបទ



ត្មាតប៉ើយគឺជាភូមិក្នុងព្រៃដាច់ស្រយាលមួយមានប្រជាជន ២៣៦គ្រួសាររស់នៅដែលមួយចំនួនក្នុងចំណោមពួកគេជាជនជាតិដើមភាគតិចគួយ ហើយភូមិនេះមានទីតាំងក្នុងតំបន់ជម្រកសត្វព្រៃគូលេនព្រហ្មទេពក្នុងខេត្តព្រះវិហារនៃតំបន់វាលទំនាបខាងជើងប្រទេសកម្ពុជា។សហគមន៍នេះរស់នៅលើជាយតំបន់ការពារ ដែលមានសុទ្ធតែព្រៃឈើជ្រុះស្លឹកតាមរដូវកាល។ នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ មានព្រៃប្រភេទនេះច្រើនកន្លែងណាស់ដែលត្រូវបានគេបម្លែងឲ្យទៅជាដីធ្វើស្រែយកស្បៀងចិញ្ចឹមជីវិត និងបំពេញសេចក្តីត្រូវការទៅតាមកំណើនប្រជាជន។ ខេត្តព្រះវិហារជាទីតាំងមួយចុងក្រោយក្នុងចំណោមកន្លែងមួយចំនួនដែលមានព្រៃឈើបែបនេះនៅសេសសល់ ហើយវាក៏ជាជម្រកដល់ពពួកសត្វព្រៃមួយចំនួនដែលរស់នៅ អាស្រ័យបានដោយសារប្រព័ន្ធអេកូឡូស៊ីនិងព្រៃឈើប្រភេទនេះដែរ។ការប្រែក្លាយព្រៃទាំងនេះឲ្យទៅជាដីកសិកម្ម (ទាំងពីសំណាក់សហគមន៍និងក្រុមឧស្សាហកម្មមកពីក្រៅ) គឺពិតជាបង្កឲ្យមានការគម្រាមកំហែងធំដល់តំបន់ការពារមួយនេះ ជាមិនខាន។

តំបន់ការពារជាច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ ត្រូវបានមនុស្សពីខាងក្រៅជាច្រើនចាត់ទុកថា ជាដីដែលអ្នកណាក៏ត្រូវការចង់បានដែរ ដោយសារថាវាមិនទាន់មានការទទួលស្គាល់ដល់របៀបប្រើប្រាស់ដីជាប្រពៃណី សិទ្ធិកាន់កាប់ជាសហគមន៍ និងសិទ្ធិក្នុងការប្រើប្រាស់ធនធានក្នុងមូលដ្ឋាននៅឡើយ។ ការរិចរឹលបាត់នូវសិទ្ធិ វាក៏បានបង្កឲ្យបាត់បង់នូវមុខងារជាមេកើយដែលធ្លាប់តែដើរតួជាប្រពៃណីក្នុងការជួយអភិរក្សបរិស្ថាន និងស្វែងរកការចិញ្ចឹមជីវិតជាមួយធម្មជាតិជុំវិញខ្លួន ហើយជាលទ្ធផលវាក៏នាំទៅដល់ការបើកតំបន់នេះដល់ការធ្វើឧស្សាហកម្ម និស្សារណកម្មប្រកបដោយបច្ច័យបំផ្លិចបំផ្លាញ។

## ជម្រកចុងក្រោយសម្រាប់សត្វព្រៃកំពុងរងការគម្រាមកំហែង

តំបន់ខ្ពង់រាបភាគខាងជើងជាទីជម្រករស់នៅបន្តពូជសត្វត្រយ៉ងយក្ស និងត្រយ៉ងចំកំកស ក្នុងចំនួន ច្រើនជាងគេបង្អស់លើពិភពលោក ហើយសត្វស្លាបទាំងពីរប្រភេទនេះស្ថិតក្នុងចំណោមពពួកសត្វកំពុងរងការគម្រាមកំហែងខ្លាំង។ តំបន់នេះក៏ទ្រទ្រង់ផងដែរដល់ការរស់រានរបស់ពពួកសត្វស្លាបស្ថិតក្រោមការគម្រាមកំហែង មួយចំនួនទៀត រួមទាំងសត្វត្មាតបីប្រភេទ (white-rumped, slender-billed and red-headed) និងសត្វស្លាបទឹក ប្រាំបីប្រភេទ (ត្រដក់ធំ, ទាព្រៃស្លាបស, ក្រៀល, ត្រដក់តូច, ពពូលទឹក, អង្គត់ខ្មៅ និងកុកពាក់អំបោះ)។ ដោយសារតែវាជាទីប្រមូលផ្តុំនូវពពួកសត្វស្លាបប្រាំបួនប្រភេទដែលកំពុងស្ថិតក្នុងស្ថានភាពគម្រាមកំហែងជាសាកលខ្ពង់រាបភាគខាងជើងជាតំបន់អភិរក្សមានលក្ខណៈវិសេសវិសាលមួយ។ តំបន់នេះទ្រទ្រង់ដល់ការរស់នៅសត្វចំនួន ៥០ ប្រភេទដែលត្រូវបានចុះក្នុងបញ្ជីក្រហមនៃពពួកសត្វស្ថិតក្រោមការគម្រាមកំហែងរបស់ អង្គការអន្តរជាតិអភិរក្សសត្វព្រៃ International Union for Conservation of Nature (IUCN)។ និយាយម្យ៉ាងទៀត តំបន់ខ្ពង់រាបភាគខាងជើងគឺជាជម្រកចុងក្រោយហើយសម្រាប់សត្វជាច្រើនក្នុងចំណោមសត្វទាំងនោះ។

## ផ្សារភ្ជាប់ការរកចំណូលរបស់អ្នកស្រុកជាមួយសុខភាពប្រព័ន្ធអេកូឡូស៊ីមូលដ្ឋាន

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្មាតប៉ើយ ធឿន ក្រសាំង បានវិវត្តន៍ចេញពីគម្រោងសាកល្បងធ្វើទេសចរណ៍ធម្មជាតិក្នុងមូលដ្ឋានភូមិត្មាតប៉ើយ ក្រោមការផ្តួចផ្តើមគំនិតរបស់អង្គការអភិរក្សសត្វព្រៃកម្ពុជា Wildlife Conservation Society (WCS)។ ភូមិត្មាតប៉ើយនេះត្រូវបានកំណត់និងជ្រើសយកមកធ្វើជាគោលដៅសម្រាប់ការសាកល្បងនេះ ដោយសារតែវាជាកន្លែងសំបូរសត្វព្រៃច្រើនប្រភេទ និងដោយសារកំណើននៃតម្រូវការរបស់អ្នកទេសចរដែលចង់មកទស្សនាសត្វជិតផុតពូជទាំងនោះនៅក្នុងទីជម្រកធម្មជាតិដែលកំពុងតែរួញតូចរបស់វា។ សហគមន៍នេះបានធ្វើការតាមបែបអភិក្រមចូលរួមជាមួយ WCS ដើម្បីបង្កើតគណៈកម្មការភូមិដោយមានការបោះឆ្នោតជ្រើសតាំង សម្រាប់គ្រប់គ្រងលើគ្រប់ផ្នែកទេសចរណ៍ធម្មជាតិ និងអ្វីដែលសំខាន់បំផុតទៅទៀតនោះ គឺគ្រប់គ្រងដីធ្លីក្នុងភូមិនោះតែម្តង។ គណៈកម្មការនេះត្រូវបានទទួលស្គាល់ស្របច្បាប់ដោយក្រសួងបរិស្ថាន និងដាក់បញ្ចូលក្រោមក្រុមប្រឹក្សាឃុំផងដែរ។

បន្ទាប់ពីគេបង្កើតគណៈកម្មការបានហើយ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយឈ្មោះថា "មជ្ឈមណ្ឌល សំ វាសនា សម្រាប់អភិរក្សសត្វព្រៃ" (Sam Veasna Center for Wildlife Conservation/SVC) ប្រចាំខេត្តសៀមរាប បានចាប់ធ្វើជាដៃគូធ្វើសកម្មភាពផ្សព្វផ្សាយលើកស្ទួយអំពីកិច្ចអភិរក្សនៅតំបន់ត្មាតប៉ើយ។ SVC ជាជម្រើសសក្តិសមមួយសម្រាប់ភាពជាដៃគូនេះ ដោយសារថាវាមានទីតាំងនៅខេត្តសៀមរាប ដែលជាមជ្ឈមណ្ឌលទេសចរណ៍របស់កម្ពុជាស្រាប់ និងដោយសារវាមានបេសកកម្មក្នុងការបន្តកេរ្តិ៍ដំណែលរបស់លោកសំវាសនា ដែលជាអ្នកមើលសត្វស្លាបនិងអ្នកអភិរក្សម្នាក់ក្នុងចំណោមអ្នកអភិរក្សដំបូងគេជាច្រើននៅកម្ពុជា។ មជ្ឈមណ្ឌល SVC បានដើរតួនាទីនាំមុខក្នុងការធានាឲ្យមានការធ្វើទេសចរណ៍បែបទទួលខុសត្រូវនៅត្មាតប៉ើយ

និងក្នុងការលើកស្ទួយកិច្ចការអភិរក្សនៅទីនោះតាមរយៈវិបសាយ បណ្ណព័ត៌មាន និងការផ្សាយពាណិជ្ជកម្ម។ គោលដៅការងារទេសចរណ៍នៅត្មាតប៉ើយគឺសំដៅលើអ្នកទេសចរថ្នាក់មធ្យមនិងខ្ពស់ និយាយឲ្យចំគឺអ្នកទាំងឡាយណាដែលចាប់អារម្មណ៍ជាមួយនឹងការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន ហើយដែលមានចេតនាហ៊ានបង់តម្លៃមួយខ្ពស់ ជាមួយនឹងការ យល់ដឹងថាចំណូលពីកម្រៃទេសចរណ៍ទាំងអម្បាលម៉ាននឹងត្រូវបានគេយកទៅវិនិយោគក្នុងការអភិវឌ្ឍសហគមន៍និងកិច្ចខិតខំអភិរក្សបរិស្ថាននិងសត្វព្រៃវិញ។ អ្នកទេសចររួមវិភាគទានដល់សេដ្ឋកិច្ចមូលដ្ឋានដោយផ្ទាល់ តាមរយៈការបង់ថ្លៃឲ្យអ្នកស្រុកសម្រាប់សេវានានា ដូចជា ការស្នាក់នៅ ការនាំភ្ញៀវ ការចំអិនអាហារ ការដឹកជញ្ជូន ហើយពួកគេក៏រួមចំណែកដោយប្រយោលផងដែរតាមរយៈវិភាគទាន ៣០ ដុល្លារអាមេរិកឲ្យទៅមូលនិធិអភិវឌ្ឍន៍ឃុំ។

គំនិតផ្តួចផ្តើមនេះបាននាំមកនូវផលប្រយោជន៍ជាច្រើន ក្នុងនោះមានការកើនឡើងនូវចំនួនសត្វព្រៃ នឹង សត្វស្លាបដែលធ្លាប់មានការទទួលគម្រាមកំហែងជិតផុតពូជ ការផ្លាស់ប្តូរជាវិជ្ជមាននូវឥរិយាបថរបស់អ្នកស្រុកចំពោះកិច្ចអភិរក្ស និងចំណូលកាន់តែច្រើនជាងមុនសម្រាប់អ្នកស្រុកក្នុងភូមិ ដែលពឹងអាស្រ័យដោយផ្ទាល់លើការការពារនិងអភិរក្សសត្វព្រៃ ធនធានធម្មជាតិនិងប្រព័ន្ធអេកូឡូស៊ី។ តាមរយៈការផ្សារភ្ជាប់កំណើនចំណូលក្នុងស្រុក ជាមួយនឹងសុខភាពប្រព័ន្ធអេកូឡូស៊ីនិងសត្វព្រៃក្នុងមូលដ្ឋាន គំរូកិច្ចអភិរក្សនេះបានសម្រេចនូវជោគជ័យក្នុងការ ផ្លាស់ប្តូរឥរិយាបថរបស់អ្នកស្រុកចំពោះសត្វព្រៃ។ ត្រង់នេះមិនមែនជាសារៈសំខាន់តូចតាចទេ ដោយហេតុថា សត្វជិតផុតពូជជាច្រើនដែលគេរកឃើញនៅតំបន់វាលរាបខាងជើងនេះ បានធ្វើជម្រក នឹងបន្តពូជក្នុងដែនដីព្រៃ កសិកម្មធម្មជាតិ ដែលផ្តល់មធ្យោបាយចិញ្ចឹមជីវិតដល់សហគមន៍មូលដ្ឋានផងដែរ។ គំរូនេះបានបង្ហាញឲ្យឃើញ ផងដែរនូវភាពទន់ភ្លន់និងស្និតស្នាញរបស់វាចំពោះមុខបញ្ហាដែលអាចកើតមានឡើងក្នុងពេលមានកាផ្លាស់ប្តូរផ្នែកគ្រប់គ្រង ព្រមជាមួយនោះវាបានដើរតួបំពេញបន្ថែមជាឧបករណ៍អភិរក្សថ្មីមួយទៀត និងជាយុទ្ធសាស្ត្រគ្រប់គ្រង ដីធ្លីផងដែរសម្រាប់សហគមន៍។

សកម្មភាពការងារទេសចរណ៍នៅត្មាតប៉ើយស្ថិតក្រោមការចាត់ចែងដោយគណៈកម្មការភូមិដែលត្រូវបាន អ្នកស្រុកបោះឆ្នោតជ្រើសតាំង។ គណៈកម្មការនេះទទួលខុសត្រូវលើការគ្រប់គ្រងចាត់ចែងផលប្រយោជន៍ទាំងអស់ ដែលបានមកពីសកម្មភាពទេសចរណ៍ និងការបញ្ចេញមូលនិធិសម្រាប់ការប្រើប្រាស់ក្នុងសហគមន៍។ នៅក្នុងភូមិ មានបួនក្រុមដែលផ្តល់សេវាដល់វិស័យទេសចរណ៍៖

1. គណៈកម្មការភូមិដែលជាប់ឆ្នោត (មានសមាជិក ១២ នាក់) ដែលមើលការខុសត្រូវខាងយាមផ្ទះសំណាក់ ភ្ញៀវ, ការបែងចែកដីដល់សមាជិកសហគមន៍ និងការរៀបចំកម្មវិធីការពារសំបុកពងសត្វស្លាប។
2. សមាគមមគ្គុទេសក៍ទេសចរណ៍ភូមិ (មានសមាជិក ១៤ នាក់) ដែលក្នុងនោះមានមគ្គុទេសក៍នាំភ្ញៀវ និងក្រុមល្បាតសហគមន៍។
3. ក្រុមធ្វើម្ហូប (មានសមាជិកបួននាក់ សុទ្ធតែជាស្ត្រី) ដែលចំអិនអាហារសម្រាប់ភ្ញៀវនិងទេសចរ។
4. ក្រុមគ្រប់គ្រងផ្ទះសំណាក់ (មានសមាជិកបួននាក់ សុទ្ធតែជាស្ត្រីដែលជាអ្នកសំអាតផ្ទះសំណាក់ និងលក់វត្ថុអនុស្សាវរីយ៍ដល់ពួកទេសចរ)។

ភាពជាមេដឹកនាំមូលដ្ឋានក៏ជាកត្តាមួយសំខាន់ណាស់ដែរក្នុងការនាំមកនូវជោគជ័យរបស់គំនិតផ្តួចផ្តើមនេះ។ លោក ឌឹប គឹមអួន ប្រធានគណៈកម្មការតំបន់ការពារសហគមន៍ត្មាតប៉ើយ ធឿន ក្រសាំង រួមជាមួយសមាជិកក្រុមដែលមានការតាំងចិត្តមុះមុតឯទៀតបានខិតខំធ្វើការដោយឥតសំចៃកម្លាំងកាយចិត្ត ដើម្បីពន្យល់អះអាងដល់សហគមន៍ឲ្យយល់អំពីផលប្រយោជន៍របស់គំរូអភិរក្សនេះ រហូតទាល់តែកៀរគរបាន បន្តិចម្តងៗ នូវការគាំទ្រពីសំណាក់មហាជនជាច្រើនក្នុងចំណោមអ្នកស្រុកភូមិទាំងនោះ។ ផ្នែកមួយសំខាន់ក្នុងកិច្ចកេណ្ឌការគាំទ្រនេះគឺការជម្រុញលើកទឹកចិត្តស្មារតីភាពជាម្ចាស់របស់សហគមន៍នឹងការបង្កើតនិងទទួលខុសត្រូវរួមគ្នាក្នុងដំណើរការទាំងមូលតែម្តង។

ភាគច្រើននៃអ្នកស្រុកនៅទីនោះជាកសិករធ្វើស្រែល្មមតែមួយរស់។ ហេតុនេះហើយ ស្ថាបត្យករគម្រោងយល់ឃើញថា ប្រការសំខាន់មិននៅត្រឹមតែការបង្ហាញដល់អ្នកស្រុកមូលដ្ឋានថាសកម្មភាពទេសចរណ៍ធម្មជាតិអាចនាំមកនូវអត្ថប្រយោជន៍និងមូលនិធិដល់ជំនាន់ក្រោយៗទៀតយ៉ាងណាខ្លះនោះទេ ប៉ុន្តែវាក៏មានផងដែរ ក្នុងការបង្ហាញឲ្យឃើញថាតើគេអាចធ្វើសមាហរណកម្មទេសចរណ៍ធម្មជាតិដូចម្តេចខ្លះទៅក្នុងផែនការប្រើប្រាស់ដីភូមិ តាមរបៀបមួយដែលអាចបន្តឆ្លើយតបបានទៅនឹងតម្រូវការសម្រាប់ធ្វើកសិកម្មចិញ្ចឹមជីវិត។ អាកប្បកិរិយា នឹងឥរិយាបថមិនមែនជារឿងងាយធ្វើឲ្យមានការផ្លាស់ប្តូរនោះទេ។ វាមិនគ្រប់គ្រាន់ទេក្នុងការប្រឹងអះអាង បញ្ចុះបញ្ចូលអ្នកស្រុកឲ្យយល់អំពីសារៈសំខាន់នៃការអភិរក្សសត្វព្រៃនោះ។ គេចាំបាច់ត្រូវតែពន្យល់អ្នកទាំងនោះឲ្យទទួលយកបានថា កិច្ចអភិរក្សអាចនឹងនាំមកនូវភាពប្រសើរប្រកបដោយអត្ថន័យដល់ការចិញ្ចឹមជីវិតនិង សុខុមាលភាពរបស់ពួកគេ។



លោក Ashish John នៃអង្គការអភិរក្សសត្វព្រៃ Wildlife Conservation Society និយាយថា៖ “អ្វីដែលខ្ញុំ ស្នើសុំនោះគឺសូមឲ្យមានការទទួលស្គាល់ថែមទៀតថា ពួកយើង ក្នុងនាមជាសហគមន៍មួយ អាចធ្វើការសម្រេចចិត្ត បានថាតើគួរបែងចែកធនធាន ជាពិសេសដីធ្លី ដោយរបៀបណាទៅឲ្យសមាជិកសហគមន៍របស់យើង។ សូមទុកឲ្យ ពួកយើងធ្វើ ហើយពួកយើងពិតជានឹងធ្វើបានល្អ”។

# សកម្មភាពសំខាន់ៗ និងការងារច្នៃប្រឌិត



យោងតាមច្បាប់តំបន់ការពាររបស់កម្ពុជា ក្រសួងបរិស្ថានត្រូវធ្វើការកំណត់ព្រំតំបន់ទ្រនាប់បួនក្នុងតំបន់ការពារធម្មជាតិទាំងមូលៈ តំបន់ទ្រនាប់គ្រប់គ្រងដោយសហគមន៍, តំបន់ទ្រនាប់ប្រើប្រាស់ធនធានដោយចីរភាព, តំបន់ទ្រនាប់សម្រាប់អភិរក្ស និងដែនតំបន់ទ្រនាប់ស្នូល។ ការកំណត់ព្រំនេះត្រូវធ្វើឡើងក្នុងតំបន់ការពារធម្មជាតិទាំង២៣ ក្នុងប្រទេស។ ជាទម្លាប់អនុវត្តន៍កន្លងមក អាជ្ញាធររបស់តំបន់ការពារធម្មជាតិ ជាទូទៅច្រើនតែធ្វើការកំណត់ព្រំតំបន់ទ្រនាប់ទាំងបួនក្នុងពេលតែមួយព្រមគ្នាតែម្តង ដែលអាចបង្កជាបញ្ហាស្មុគ្រស្មាញដល់ផែនការប្រើប្រាស់ដីធ្លី ហើយជាញឹកញាប់នាំទៅដល់ការប្រែក្លាយព្រៃឬតំបន់អភិរក្សដទៃទៀតសម្រាប់ការប្រើប្រាស់ក្នុងវិស័យកសិកម្មទៅវិញ។

## សង្វាក់ការងារកំណត់ព្រំដី

ត្នាតប៉ើយជាភូមិទីមួយក្នុងដែនជម្រកសត្វព្រៃគូលេនព្រហ្មទេពដែលសកម្មក្នុងការកំណត់ព្រំតំបន់ទ្រនាប់ក្នុងសហគមន៍របស់គេ។ ធ្វើដូច្នេះ គណៈកម្មការអាចដឹកនាំការងារក្នុងដំណើរការដែលមានការចូលរួម ដែលតាមរយៈនេះជម្រុញស្មារតីភាពជាម្ចាស់ស្រុក និងប្រឡូកភាគីពាក់ព័ន្ធដទៃទៀតក្នុងការងារនេះ(មានដូចជាសហគមន៍,WCS,អាជ្ញាធរខេត្តនិងបុគ្គលិកក្រសួងបរិស្ថាន)។ តាមរយៈនេះគេអាចសម្រាលបាននូវវិវាទដែលអាចកើតមានរវាងសមាជិកសហគមន៍និងអាជ្ញាធរដែនការពារធម្មជាតិលើកន្លែងណាដែលគេមិនទាន់បានវាស់ព្រំកំណត់នៅឡើយ។ ដោយសារថាមិនទាន់មានមគ្គុទេសក៍ណែនាំអំពីសង្វាក់ដំណើរការកំណត់ព្រំតំបន់ទ្រនាប់ បទពិសោធន៍នៅត្នាតប៉ើយអាចជាគំរូសំខាន់មួយ ក្នុងការកំណត់ព្រំតំបន់ទ្រនាប់គ្រប់គ្រងដោយសហគមន៍ជាមុនជាជម្រើសជំនួសឲ្យការធ្វើកំណត់ព្រំតំបន់ទ្រនាប់ទាំងបួនក្នុងពេលតែមួយព្រមគ្នា។ ការអនុវត្តបែបនេះ ដូចជាការកំណត់ជាមុននូវផែនការប្រើប្រាស់ដីសហគមន៍ ត្រូវបានគេចម្លងយកទៅអនុវត្តន៍តាមនៅភូមិប្រាំ និង ឃុំមួយទៀត។

ភូមិត្នាតប៉ើយបានអនុវត្តន៍ដោយជោគជ័យនូវការផ្សារភ្ជាប់កិច្ចអភិរក្សសត្វស្លាបជាមួយឧស្សាហកម្មទេសចរណ៍ តាមរយៈកិច្ចព្រមព្រៀងមួយរវាងសហគមន៍ដែនជម្រកសត្វព្រៃ និងអង្គការ WCS ។ កិច្ចព្រមព្រៀងបានចែងថា ចំណូលទេសចរណ៍សម្រាប់ភូមិនេះវាចំណុះទៅនឹងការដែលអ្នកស្រុកភូមិឯកភាពយល់ព្រមធ្វើការ គ្រប់គ្រងប្រកបដោយចីរភាពនូវជម្រកសត្វ និងការពារសត្វព្រៃទាំងនោះ តាមរយៈផែនការលម្អិតក្នុងការប្រើប្រាស់ដីភូមិ និងគោលនយោបាយម៉ឹងម៉ាត់មួយដែលបំរាមការបរបាញ់សត្វ។ ផែនការប្រើប្រាស់ដីមានភាពស្របច្បាប់លើមូលដ្ឋានការកំណត់តំបន់ទ្រនាប់ដែលអនុម័តដោយរដ្ឋាភិបាល។ ផែនការនេះត្រូវបានសម្រេចតាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍ ហើយវាកំណត់ច្បាស់លាស់នូវទីតាំងដីប្រើប្រាស់សម្រាប់កសិកម្ម លំនៅដ្ឋាន និងការទាញយកផលពីធនធានធម្មជាតិប្រកបដោយចីរភាព។

## បព្រក់ឧបត្ថម្ភលើកទឹកចិត្តដល់សកម្មភាពអភិរក្ស

គោលនយោបាយបំរាមការបរបាញ់សត្វរបស់ភូមិត្នាតប៉ើយត្រូវបានអមដោយគោលការណ៍មួយដែលបង់ប្រាក់ឲ្យសមាជិកសហគមន៍ ដើម្បីកុំឲ្យពួកគេទៅយកពងសត្វ ឬចាប់កូនបក្សីនៃពពួកសត្វកំពុងស្ថិតក្នុងការគម្រាមកំហែងពីទីតាំងសំបុករបស់វា។ ទីផ្សារងងឹតមួយធ្លាប់បានកើតមាននៅតាមព្រំដែនថៃ-ឡាវ សម្រាប់ជួញដូរពងសត្វស្លាបដែលកំពុងស្ថិតក្នុងការគម្រាមកំហែង ដោយមានឈ្មួញកណ្តាលជាអ្នកសម្របសម្រួល។ ពងសត្វក្រៀលជាពិសេស ស្ថិតក្នុងចំណោមពងដែលលក់បានថ្លៃខ្ពស់។ ជាការឆ្លើយតបភូមិត្នាតប៉ើយបានដើរតួនាទីនាំមុខក្នុងគំនិតផ្តួចផ្តើមមួយមានឈ្មោះថា "កម្មវិធីការពារសំបុកសត្វស្លាប" ដែលកេណ្ឌអ្នកស្រុកក្នុងភូមិឲ្យចូលរួមក្នុងការដើររកទីតាំងតាមដាន និងការពារសំបុកសត្វ។ គំនិតនេះបានផ្តើមចេញជាដំបូងពី WCS តែ ការទទួលខុសត្រូវកាន់តែច្រើនឡើងត្រូវបានផ្ទេរទៅឲ្យភូមិត្នាតប៉ើយ ព្រោះបទពិសោធន៍បានបង្ហាញថា តាមរយៈ កិច្ចសហការដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន គេអាចរកឃើញសំបុកសត្វស្លាបក្នុងចំនួនច្រើនហើយការពារវាបានដោយជោគជ័យទៀតផង។ ក្រោមកម្មវិធីនេះ សមាជិកសហគមន៍ទទួលបានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ (ជារង្វាន់ប្រាក់ដល់ទៅ ៥ ដុល្លារអាមេរិក) ជាថ្នូរទៅនឹងការដែលគេរាយការណ៍អំពីសំបុកសត្វស្លាប និងការដែល គេដើរតួជាអ្នកឃ្លាំមើលការពារទីតាំងសំបុកនោះរហូតដល់កូនសត្វញាស់និងលូតលាស់ពេញរូបរាប។ អ្នកឃ្លាំមើល ទទួលបាន ១ ដុល្លារអាមេរិកក្នុងមយយថ្ងៃ ហើយពួកគេទទួលបានប្រាក់ ១ ដុល្លារ ថែមពីលើទៀតបន្ទាប់ពីកូនសត្វ ធំពេញរូបរាង។ គេក៏នៅតែបង់ថ្លៃពេញដល់អ្នកឃ្លាំមើលសំបុកដែរ បើសិនជាគេអាចធ្វើផ្ទៀតផ្ទាត់រកឃើញថា សំបុកសត្វខូចដោយមូលហេតុធម្មជាតិ ដូចជាត្រូវបានសត្វព្រៃដទៃស៊ីជាអាហារជាដើម។ អាត្រាកម្រៃប្រាក់នេះត្រូវគេព្រមព្រៀងគ្នាតាមរយៈការពិភាក្សាជាមួយសហគមន៍។ កម្មវិធីប្រាក់លើកទឹកចិត្តនេះត្រូវបានអមបំពេញដោយ កម្មវិធីមួយទៀតដែលគណៈកម្មការភូមិត្នាតប៉ើយជាអ្នកចាត់ចែង ហើយក្នុងនោះគេប្រើចំណូលពីទេសចរណ៍ធម្មជាតិបង់កម្រៃ១០ទៅ១៣ដុល្លារក្នុងមួយឆ្នាំដល់ម្ចាស់ដើមឈើជ័រទឹក ឲ្យជួយការពារទីតាំងសំបុកសត្វ។ សត្វត្រដក់ ជាពិសេសចូលចិត្តកាច់សំបុកលើដើមឈើជ័រទឹក ដែលជាប្រភពចំណូលសំខាន់មួយរបស់អ្នកស្រុក។

ការងារច្នៃប្រឌិតមួយទៀតដែលគួរកត់សម្គាល់ដែរនោះគឺកម្មវិធីបង់ថ្លៃទូទាត់កសិ-បរិស្ថាន ដែលត្រូវបានចាប់ផ្តើមកាលពីឆ្នាំ ២០០៧។ ក្រោមកម្មវិធីនេះ កសិករណាដែលអនុលោមបានតាមផែនការប្រើប្រាស់ដីក្នុងភូមិ និងបំរាមបរបាញ់សត្វ អាចទទួលបានសិទ្ធិចូលរួមក្នុងសមាគមទីផ្សារដែលតាមរយៈនេះ ពួកគេអាចលក់ស្រូវរបស់គេក្នុងតម្លៃមួយខ្ពស់ជាងធម្មតា។ សមាគមទីផ្សារមិនគ្រាន់តែផ្តល់ដល់សមាជិករបស់ខ្លួននូវតម្លៃស្រូវអនុគ្រោះពិសេសប៉ុណ្ណោះទេ ប៉ុន្តែវាបានដើរតួជាអ្នកប្រមូលទិញផលិតផលរបស់អ្នកស្រុកសម្រាប់លក់ឲ្យទីផ្សារជាតិ ដោយផ្ទាល់តែម្តង ដោយមិនបាច់ឆ្លងកាត់ឈ្មួញកណ្តាលដែលធ្លាប់តែកាន់កាប់ផ្តាច់មុខនូវជំនួញរកស៊ីរបស់អ្នកភូមិ។ លើសពីនេះទៀត សមាគមនេះជួយផ្តល់ផងដែរនូវដើមទុនដំបូងដល់សហគ្រាសធន់តូចប្រកបរបរណាដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសថ្មីក្នុងការធ្វើកសិកម្ម។ប្រាក់ចំណេញដែលរកបានគេយកទៅចែករំលែកជាមួយកសិករនិងសមាគមនានាដែលជាសមាជិក។

គណៈកម្មការតំបន់ការពារធម្មជាតិត្មាតប៉ើយ ធឿន ក្រសាំង បានបង្កើត និងអនុវត្តន៍ផែនការប្រើប្រាស់ដីសហគមន៍ និងដាក់ចេញនូវកម្មវិធីនានាសម្រាប់កិច្ចអភិរក្សទីតាំងសំបុកនិងរកចំណីរបស់ពពួកសត្វស្លាបដែលរងការគម្រាមកំហែងជិតផុតពូជជាសាកល។ តាមរយៈការងារគណៈកម្មការសមាជិកសហគមមានភាពអង់អាចក្នុងការអនុវត្តក្រិតក្រមផែនការប្រើប្រាស់ដីក្នុងមូលដ្ឋានរួមមានការ ត្រួតពិនិត្យលើសកម្មភាពកាប់ឆ្ការព្រៃយកដីធ្វើកសិកម្ម។ តាមធម្មតាកិច្ចសន្យាជាពាក្យសំដីឬលាយលក្ខអក្សររវាងបុគ្គលនិងគណៈកម្មការជាមូលដ្ឋានសម្រាប់ការអនុវត្តក្រិតក្រមនេះដើម្បីបញ្ឈប់សកម្មភាពស្មើសច្បាប់ ឬក៏ផ្លាស់ប្តូរទីតាំងដីធ្វើកសិកម្មទៅតាមផែនការប្រើប្រាស់ដី។

វានៅតែមានភាពចាំបាច់ឲ្យមានការបន្តផ្តល់កម្រៃលើកទឹកចិត្តសម្រាប់អនុវត្តន៍ក្រិតក្រមក្នុងការងារអភិរក្សតទៅទៀត ដោយសារថាតម្លៃដីធ្លីដែលចេះតែបន្តកើនបានកាន់តែជម្រុញឲ្យមានការចាប់ដណ្តើមដីធ្លីកាន់តែខ្លាំងថែមទៀត។ យ៉ាងណាក្តី មកទល់បច្ចុប្បន្ន វិធីអភិរក្សតាមការចូលរួមរបស់សហគមន៍នេះ បាននាំមកនូវភាពប្រសើរជាដុំកំភួនជាងមុនច្រើនក្នុងជីវភាពរស់នៅរបស់អ្នកស្រុក និងក្នុងភាពសំបូរបែបរបស់សត្វព្រៃក្នុងមូលដ្ឋានផងដែរ។ កម្មវិធីទេសចរណ៍ធម្មជាតិបានបង្ហាញដល់អ្នកស្រុកមូលដ្ឋានអំពីសារៈសំខាន់ពពួកសត្វព្រៃកម្រ និងតម្លៃសេដ្ឋកិច្ចក្នុងការអភិរក្សសត្វទាំងនោះ។

ក្នុងន័យស្ថាប័នគំនិតផ្តួចផ្តើមនេះពឹងផ្អែកលើភាគីបួនដែលមានតួនាទីសំខាន់រៀងៗខ្លួន។ គណៈកម្មការតំបន់ការពារធម្មជាតិត្មាតប៉ើយ ធឿន ក្រសាំង ទទួលខុសត្រូវលើការគ្រប់គ្រងសេវាកម្មទេសចរចំណូលដែលរកបាន មូលនិធិដែលត្រូវបានបែងចែក ការអនុវត្តផែនការប្រើប្រាស់ដីនិងកិច្ចសន្យាមិនប្រមាញ់សត្វព្រៃ និងរាយកាណ៍អំពីការរំលោភនានាទៅឲ្យអាជ្ញាធរតំបន់ការពារធម្មជាតិ។ អាជ្ញាធរតំបន់ការពារធម្មជាតិទទួលខុសត្រូវលើការធ្វើឲ្យមានភាពប្រសើរក្នុងកិច្ចព្រមព្រៀងទេសចរ និងលើការអនុវត្តច្បាប់សិទ្ធិកាន់កាប់ដីធ្លី។មជ្ឈមណ្ឌលសំរាំសនា ជាអ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយទីផ្សារអំពីទេសចរធម្មជាតិនៅតំបន់អភិរក្សនោះ ការទាក់ទាញចុះបញ្ជីភ្ញៀវទេសចរមកទស្សនា និងធ្វើការត្រួតពិនិត្យសហគ្រាសនេះជំនួសមុខឲ្យសហគ្រាស។ ចុងក្រោយគេបង្អស់ភាគីផ្សេងៗទៀតក្នុងវិស័យឯកជនផ្តល់ការចុះបញ្ជីទេសចរដែលជាប្រភពដើមគេសម្រាប់ចំណូលដែលជម្រុញលើកទឹកចិត្តកិច្ចខិតខំធ្វើការអភិរក្សនៅទីនោះ។



# ឥទ្ធិពល



## ឥទ្ធិពលមកលើជីវៈចម្រុះ

ត្រយ៉ង (Pseudibisgigantea) ជាសត្វជាតិរបស់កម្ពុជា។ សម្រាប់អ្នកមើលបក្សី និងអ្នកអភិរក្ស វាជាប្រភេទសត្វស្លាបមួយដ៏កម្រវិសេសវិសាលមែនទែន។ គេបានដឹងអំពីវាតាមរយៈការឃើញម្តងម្កាលពីមុនមកហើយការស្រាវជ្រាវមួយរបស់WCSនៅឆ្នាំ២០០០បានលាតត្រដាងឲ្យគេដឹងកាន់តែច្បាស់ថាសត្វនេះនៅមានបន្តអត្ថិភាពរបស់វានៅតំបន់វាលរាបខាងជើងនៅឡើយទេ។ ដោយមានការគាំទ្រពីសំណាក់គណៈកម្មការ នៅមូលដ្ឋាន WCS ធ្វើការស្រង់ចំនួនសត្វត្រដក់ ក្រៀល ត្នាត និងប្រភេទសត្វស្លាបសំខាន់ៗផ្សេងទៀតនៅទីនោះជារៀងរាល់ឆ្នាំ។ អង្គការ WCS ក៏មានក្រុមស្រាវជ្រាវមួយផងដែរដែលត្រួតពិនិត្យមើលសំបុក និងសត្វព្រៃនានាក្នុងតំបន់នោះ។ សកម្មភាពទាំងនេះផ្តល់នូវព័ត៌មានគួរជឿទុកចិត្តបានអំពីការកើនឬការថយចុះ ក្នុងចំនួនសត្វព្រៃសំខាន់ៗ (ដូចដែលមានបង្ហាញក្នុងរូបតារាង១និង២នៅខាងក្រោម)។

នៅឆ្នាំ២០០៣បុគ្គលិករបស់WCSបានរកឃើញកន្លែងបន្តពូជសត្វត្រដក់កសមួយគូនៅត្មាតប៉ើយ។ នាពេលនោះ គេដឹងថាវាជាកន្លែងបន្តពូជតែមួយគត់របស់សត្វនេះនៅដែនដីគោកអាស៊ី។ តែចាប់ពីពេលនោះមកចំនួនរបស់វានៅក្នុងតំបន់នោះ បានកើនពី ១សំបុក និងសត្វក្រៀលមួយគូ រហូតដល់ទៅ ៦សំបុកនិងសត្វក្រៀល២៣ក្បាលក្នុងឆ្នាំ២០០៨។ ការតាមដានពិនិត្យរបស់ WCS ក៏បានបង្ហាញដែរថា ចំនួនសត្វត្រដក់ធំបន្តពូជក៏មានច្រើនដែរនៅទីនោះ
គឺគេឃើញមានរហូតដល់ទៅ ៤១គូឯណោះក្នុងឆ្នាំ ២០០៩។

ជាមួយគ្នានេះដែរ គណៈកម្មការតំបន់ការពារធម្មជាតិត្មាតប៉ើយ ធឿន ក្រសាំង ក៏បានធ្វើការងារផ្សព្វផ្សាយលើកកំពស់ការយល់ដឹងរបស់សហគមន៍ អំពីវត្តមានរបស់ពពួកសត្វនៅទីនោះផងដែរ។ តាមរយៈគណៈកម្មការ សហគមន៍មានការប្តេជ្ញាចិត្តចំពោះកិច្ចអភិរក្សសត្វស្លាបធំៗដែលរងការគម្រាមកំហែងជាសាកលដែលគេរកឃើញនៅត្មាតប៉ើយ ដោយប្រើសត្វត្រយ៉ងជានិមិត្តរូបក្នុងគោលដៅរបស់ខ្លួន។ វិធីនេះ ដែលសហគមន៍ជ្រើសរើសយកសម្រាប់កិច្ចអភិរក្សសត្វព្រៃក្នុងមូលដ្ឋានតាមរយៈការងារទេសចរណ៍ធម្មជាតិត្រូវបានពង្រីកទៅប្រើលើទីតាំង ៧ ទៀតក្នុងប្រទេសកម្ពុជា ហើយគេមានគម្រោងនឹងពង្រីកវាទៅកន្លែងផ្សេងទៀតនៅថ្ងៃមុខ។

ព្រៃនៅខ្ពង់រាបខាងជើងក៏ជួយទ្រទ្រង់ផងដែរដល់ការរស់នៅរបស់សត្វជិត

**Fig. 1: Increases in White-shouldered and Giant Ibis populations in Tmatboey, 2002-2009**




*LEFT: White-shouldered Ibis populations at Tmatboey, 2002-2008. Source: T. Clements et al., 2010. RIGHT: Giant Ibis breeding success 2003-2009. Source: WCS internal report, 2009.*

ផុតពូជប្រភេទផ្សេងទៀត ដូចជាសត្វក្តាន់អំបូរ Eld's deer (Rucervus eldii) ដែលសឹងតែលែងមានទៅហើយនៅលើពិភពលោកនេះ។ កិច្ចព្រមព្រៀងអភិរក្សជាមួយសហគមន៍បានជួយដល់ការការពារសត្វជិតផុតពូជមួយនេះ។ គណៈកម្មការនិងសមាជិកសហគមន៍បានប្រកាន់យកការទទួលខុសត្រូវផ្នែកច្បាប់ពេញលេញសម្រាប់ការគ្រប់គ្រងសត្វព្រៃ និងដីនៅជុំវិញភូមិ ហើយជាលទ្ធផល កម្រិតនៃការកាប់បំផ្លាញព្រៃឈើនិងការទន្ទ្រានចូលជម្រកសត្វព្រៃមានការថយចុះ ដោយសារថាសហគមន៍បាននាំគ្នាគោរពតាមព្រំដែនកំណត់ក្នុងការប្រើប្រាស់ដីធ្លី។

## *ឥទ្ធិពលខាងសេដ្ឋកិច្ចសង្គម*

ការអភិវឌ្ឍទេសចរណ៍នៅត្មាតប៉ើយដោយផ្អែកលើការអភិរក្សសត្វស្លាបកម្របានធ្វើឲ្យមានការប្រែប្រួល ប្រសើរយ៉ាងខ្លាំងក្នុងចំណូលថវិកាសមាជិកសហគមន៍ ដោយវាបានផ្តល់ឲ្យពួកគេនូវឱកាសការងារច្រើនជាងមុន និងប្រភពរកចំណូលសម្រាប់មូលនិធិអភិវឌ្ឍន៍ឃុំ។

ចំនួនទេសចរទៅមើលត្មាតប៉ើយមានការកើនឡើងជាមធ្យម ៣៦ ភាគរយក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៥ មក។ ក្នុងរយៈពេលដូចគ្នានេះ ចំណូលក៏កើនឡើងជាមធ្យម ១០០ភាគរយ ក្នុងមួយឆ្នាំ ដែរ។ អ្នកស្រុក បាននាំគ្នាកែលម្អឲ្យប្រសើរឡើងនូវគុណភាពសេវាដែលអនុញ្ញាតពួកគេឲ្យតម្លើងថ្លៃទស្សនា ហើយបានធ្វើពិពិធកម្ម សេវារបស់ខ្លួនដើម្បីពង្រីកសមាមាត្រក្នុងខ្សែសង្វាក់តម្លៃពីទេសចរណ៍ផងដែរ។ ជាមធ្យម តម្លៃសេវាដែលទេសចរ បង់ក្នុងម្នាក់ៗ បានកើនពី ១០ ដុល្លារ ក្នុងឆ្នាំ ២០០៤ ដល់ ៦៧ ដុល្លារ ក្នុងឆ្នាំ ២០០៨។ ក្នុងរយៈពេលដដែលនោះ ភាគរយនៃចំណាយក្នុងមូលដ្ឋានពីចំណូលទេសចរណ៍បានកើនពី ១១ភាគរយ ដល់ ២៤ភាគរយ ឯណោះ។

មកត្រឹមឆ្នាំ ២០០៧-២០០៨ ភូមិត្មាតប៉ើយទទួលបានចំណូល ១២.០០០ ដុល្លារ ពីសកម្មភាពទេសចរ ដែលក្នុងនោះ ចំនួន ៣.៥០០ បានមកពីវិភាគទានដល់មូលនិធិភូមិ ហើយជិត ៨.៥០០ ដុល្លារ ដែលបានមកពីថ្លៃទេសចរបង់ទៅលើសេវាដែលអ្នកភូមិបានផ្តល់ជូនក្នុងពេលស្នាក់នៅ របស់ពួកគេ។ រវាងឆ្នាំ ២០០៧-២០០៨ មាន មនុស្សចំនួន ២៥ នាក់មកពី ២៣៦ គ្រួសារ ត្រូវបានគេជួលមកធ្វើការពាក់កណ្តាលអចិន្ត្រៃសម្រាប់ធ្វើជាអ្នកនាំភ្ញៀវ ចុងភៅ និងអ្នកគ្រប់គ្រងផ្ទះសំណាក់ ដោយក្នុងម្នាក់ទទួលបានកម្រៃជាមធ្យមពី ២០ ទៅ ៤០ ដុល្លារក្នុងមួយ ខែ ក្នុងរដូវទេសចរណ៍ (ឬក៏ជាមធ្យម ១៦០ ដុល្លារ ទៅ ៤០០ ដុល្លារ ក្នុងមួយឆ្នាំ)។ នេះជាបរិមាណទឹកលុយមួយ ច្រើនគួរសមដែរសម្រាប់គ្រួសាររបស់អ្នកទាំងនោះ ដែលតាមធម្មតាពឹងតែទៅលើកសិកម្មចិញ្ចឹមក្រពះ និងការប្រមូលផលព្រៃ នៅក្នុងតំបន់មួយដែលប្រជាជនមានចំណូលសាច់ប្រាក់ក្នុងមួយគ្រួសារជាមធ្យម តែពី ៣០០ ទៅ ៥០០ ដុល្លារ ប៉ុណ្ណោះក្នុងមួយឆ្នាំ។ ក្រៅពីនោះ មានមនុស្ស ៦៥ នាក់ផ្សេងទៀតបានទទួលប្រយោជន៍ តាមរយៈការងារជាបណ្តោះអាសន្ន ដូចជាធ្វើជាអ្នកនាំភ្ញៀវម្តងម្កាល ជាអ្នកសម្អាតផ្ទះសំណាក់ ដងទឹក ឬមួយតាមរយៈការធ្វើជំនួញ ជាពិសេស ម្ហូបអាហារ ក្នុងភូមិ។ ដូច្នេះ សរុបមក ជិត ៤០ ភាគរយនៃគ្រួសារក្នុងភូមិបានប្រឡូក ពាក់ព័ន្ធ ដោយកម្រិតផ្សេងៗគ្នា ក្នុងសកម្មភាពកិច្ចអភិរក្សនេះ។ អំណោយពីទេសចរដល់មូលនិធិភូមិត្រូវបានគេយកទៅប្រើប្រាស់ដើម្បីសង់សាលារៀនថ្មី ធ្វើផ្លូវ ជីកស្រះត្រី ជួសជុលស្នប់ទឹក និងជីកអណ្តូងថ្មី។ លុយខ្លះពីប្រាក់ ចំណេញនោះត្រូវបានគណៈកម្មការប្រើបង់កម្រៃឲ្យអ្នកភូមិសម្រាប់ដើរល្បាតនិងការពារសំបុកសត្វ។គេក៏បានប្រើលុយនេះសម្រាប់ជួសជុលនិងថែទាំដំណាក់ទេសចរ ក្នុងមានការផ្លាស់ដំបូលស្បូវរបស់បន្ទប់ផ្ទះសំណាក់ ជាដើម។ តាមទំនៀមទំម្លាប់ វប្បធម៌ជាប្រពៃណីនៅកម្ពុជា ស្ត្រីនិងកុមារីតែងតែជាអ្នកដែលត្រូវរ៉ាប់រងកិច្ចការផ្ទះសម្លៀងយូរម៉ោង




Fig. 2: ចំណូលពីទេសចរណ៍ធម្មជាតិ និងចំនួនអ្នកទេសចរ ពីឆ្នាំ ២០០៣ ដល់២០១០




*Source: WCS internal report, 2010*

ហើយច្រើនមុខ ដែលជាលទ្ធផលធ្វើឲ្យក្មេងស្រីមិនទទួលបានការរៀនសូត្រខ្ពង់ខ្ពស់ ហើយគ្រួសារច្រើននិយមបញ្ជូនកូនប្រុសឲ្យទៅរៀនជាងកូនស្រី។ ភូមិត្បាតប៉ើយមានសាលាបឋមសិក្សាតែមួយខ្នងទេ ហើយមានក្មេងៗតិចនាក់ណាស់ដែលបានរៀនបន្តរហូតដល់កម្រិតមធ្យមសិក្សាបឋមភូមិ។ បើទោះជាគណៈកម្មការនេះមានភាគច្រើនជាបុរសក្តី កិច្ចខិតខំជាច្រើនត្រូវបានធ្វើដើម្បីបញ្ចូលស្ត្រីទៅក្នុងសកម្មភាពនានា និងក្នុងជួរគ្រប់គ្រងអភិបាលកិច្ចរបស់គណៈកម្មការ។ គណៈកម្មការទេសចរណ៍ធម្មជាតិនេះ ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតបែបប្រជាធិបតេយ្យ ហើយបច្ចុប្បន្នមានតំណាងជាស្ត្រីពីររូប។

ក្រុមស្ត្រីជួយខ្លួនឯងមួយត្រូវបានបង្កើតឡើងដើម្បីលក់ទំនិញនានា ដូចជាភេសជ្ជៈ អាហារ អាវយឺត និងវត្ថុសិប្បកម្ម ដល់អ្នកទេសចរ។ ក្រុមចុងភៅដែលធ្វើម្ហូបឲ្យភ្ញៀវមានស្ត្រីបួននាក់ ហើយក្រុមគ្រប់គ្រងផ្ទះសំណាក់ក៏មានសុទ្ធតែនារីចំនួនបួននាក់ផងដែរ។

ការបញ្ចូលពលរដ្ឋដែលមានស្ថានភាពយ៉ាប់យ៉ឺនជាងគេក្នុងចំណោមអ្នកក្រីក្រទៅក្នុងការអនុវត្តចាត់ចែងគម្រោងនេះ ត្រូវបានទទួលការលើកទឹកចិត្តតាមរយៈដំណើរការប្រជាធិបតេយ្យ ដែលក្នុងនោះសេចក្តីសម្រេចនានា រួមទាំងការបែងចែកចំណូលទេសចរណ៍ផង ត្រូវបានគេធ្វើឡើងតាមការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ទាំងអស់។

## ឥទ្ធិពលខាងគោលនយោបាយ

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្បាតប៉ើយ ធឿន ក្រសាំង ត្រូវបានអាជ្ញាធរខេត្តទទួលស្គាល់ថាជា ឧទាហរណ៍ទម្លាប់អនុវត្តន៍ដ៏ប្រពៃមួយជាពិសេសក្នុងកិច្ចការរៀបចំតំបន់ទ្រនាប់ក្នុងសហគមន៍ និងការចម្លងគំរូនេះដោយជោគជ័យយកទៅអនុវត្តន៍នៅភូមិផ្សេងទៀតក្នុងដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព។ ប្រធានមន្ទីរបរិស្ថានខេត្តបានជម្រុញលើកកម្ពស់គំរូអភិរក្សនៅត្បាតប៉ើយ ដែលក្នុងនោះតំបន់ទ្រនាប់គ្រប់គ្រងដោយសហគមន៍ត្រូវបានកំណត់ព្រំមុនគេ មុននឹងមានការបែងចែកតំបន់ទ្រនាប់ដទៃសម្រាប់ការប្រើប្រាស់ផ្សេងទៀត។ ថ្នាក់ដឹកនាំមន្ទីរបរិស្ថានខេត្តក៏បានឲ្យដំបូន្មានថែមទៀតថា គំរូនេះគួរតែត្រូវបានចម្លងយកទៅអនុវត្តន៍នៅជម្រកសត្វព្រៃផ្សេងទៀតនៅក្នុងខេត្ត។

ក្រសួងបរិស្ថានក៏កំពុងផ្តល់ការគាំទ្រផងដែរដល់សកម្មភាពទាំងឡាយរបស់សហគមន៍ត្បាតប៉ើយ ធឿន ក្រសាំង ដោយតាមដានជិតដល់នូវវឌ្ឍនភាពរបស់វាក្នុងគោលបំណងយកវាធ្វើជាគំរូទប្រើនៅជម្រកសត្វព្រៃផ្សេងទៀត។ មានការរំពឹងទុកថា ត្បាតប៉ើយនឹងត្រូវបានគេយកទៅប្រើជាគំរូសម្រាប់កិច្ចអភិវឌ្ឍន៍កម្រិតជាតិនូវដំណើរការនីតិវិធី សម្រាប់កំណត់ផែនទីតំបន់ទ្រនាប់សហគមន៍។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានធ្លាប់បានលើកឡើងជាច្រើនដងថាភូមិត្បាតប៉ើយជាគំរូឧទាហរណ៍មួយសម្រាប់ការធ្វើទេសចរណ៍ធម្មជាតិ។ ឯកឧត្តមបានធ្វើទស្សនកិច្ចនៅទីនោះ ពីរដងដើម្បីសម្តែងការគាំទ្រដល់សហគមន៍ ហើយថែមទាំងបានប្រគល់ដល់ភូមិនោះនូវមេដៃទទួលស្គាល់នូវការងារអភិរក្សដ៏លេចធ្លោរបស់អ្នកស្រុកផងដែរ។



# និរន្តរភាព និង ការចម្លងទៅអនុវត្តកន្លែងផ្សេង



## *និរន្តរភាព*

ធាតុផ្សំមួយសំខាន់ក្នុងចំណោមធាតុផ្សំឯទៀតរបស់និរន្តរភាពនៃកិច្ចផ្តួចផ្តើមអភិរក្សត្មាតប៉ើយ គឺនៅត្រង់ការដែលសហគមន៍ឲ្យតម្លៃខ្ពស់ចំពោះសម្ពន្ធអាស្រ័យទាក់ទងនៃសេដ្ឋកិច្ចទេសចរណ៍ធម្មជាតិនិងកិច្ចអភិរក្សជីវៈចម្រុះនៅទីនោះ។សមាជិកសហគមន៍ដឹងយ៉ាងច្បាស់ថាអ្នកទេសចរទៅទស្សនាភូមិរបស់គេដើម្បីទៅចាំឃ្លាំមើលពពួកសត្វស្លាបកំពុងរងគ្រោះជិតផុតពូជ ហើយដើម្បីរក្សាផលប្រយោជន៍សហគមន៍ឲ្យបានយូរអង្វែង ពួកគេត្រូវចាត់វិធានការគ្រប់គ្រងការប្រើប្រាស់ដី ដើម្បីធានាឲ្យបាននូវការការពារដល់ពពួកសត្វទាំងនោះ។ចំណូលបានមកពីទេសចរណ៍ធម្មជាតិត្រូវបានគេប្រើប្រាស់សម្រាប់ធានាឲ្យបាននូវចីរភាពសកម្មភាពទេសចរណ៍ ធម្មជាតិ និងការអនុវត្តផែនការប្រើប្រាស់ដីធ្លី។ ដរាបណាពួកទេសចរនៅតែបន្តទស្សនកិច្ចតំបន់នោះ គម្រោងនឹងនៅមាននិរន្តរភាព ទាំងផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម។

ធាតុផ្សំសំខាន់មួយទៀតនៃនិរន្តរភាពគម្រោង គឺកម្រិតខ្ពស់នៃភាពជាម្ចាស់របស់សហគមន៍លើកម្មវិធីសកម្មភាពទាំងឡាយ និងការចូលរួមរបស់ពួកគេក្នុងដំណើរការធ្វើសេចក្តីសម្រេច។ ក្រៅតែពីការលើកទឹកចិត្តពីសំណាក់ផលប្រយោជន៍ហិរញ្ញវត្ថុ សហគមន៍នេះមានភាពអង់អាច និងមោទនភាពជាមួយនឹងលទ្ធផលជាវិជ្ជមាន ជាច្រើនដែលពួកគេសម្រេចបានតាមរយៈកិច្ចផ្តួចផ្តើមនេះ។

គំរូភាពជាដៃគូនេះមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យគំនិតផ្តួចផ្តើមនេះមាននិរន្តរភាពមកដល់បច្ចុប្បន្ន។ អង្គការការពារសត្វព្រៃ WCS ធ្វើការជាដៃគូជាមួយក្រសួងបរិស្ថានដើម្បីគ្រប់គ្រងចាត់ចែងដែនជម្រកសត្វព្រៃ គូលេនព្រហ្មទេព ហើយភាពជាដៃគូនេះមានសារៈសំខាន់ជាគន្លឹះសម្រាប់ជោគជ័យរបស់គម្រោង។ មជ្ឈមណ្ឌល សំ វាសនា ដើម្បីកិច្ចអភិរក្ស បានធ្វើការកសាងសមត្ថភាពដល់សសហគមន៍មូលដ្ឋានឲ្យចេះកែលម្អសេវាកម្មជូនអ្នកទេសចរ និងទាក់ទាញអ្នកមើលសត្វស្លាបឲ្យមកទស្សនាភូមិត្មាតប៉ើយ។

## *ការចម្លងទៅអនុវត្តកន្លែងផ្សេង*

បើនិយាយអំពីការងារកំណត់ដែនតំបន់ទ្រនាប់សហគមន៍របៀបដែលប្រើនៅត្មាតប៉ើយ - ដែលនៅទីនោះ តំបន់ទ្រនាប់គ្រប់គ្រងដោយសហគមន៍ត្រូវបានគូសព្រំកំនត់មុនតំបន់ទ្រនាប់ដទៃទៀត - ត្រូវបានអាជ្ញាធរខេត្ត ទទួលស្គាល់ថាជាឧទាហរណ៍មួយនៃទម្លាប់អនុវត្តន៍ល្អ ហើយវាត្រូវបានចម្លងយកទៅអនុវត្តន៍ដោយជោគជ័យ នៅភូមិឯទៀតក្នុងរង្វង់ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព។ ប្រធានមន្ទីរបរិស្ថានខេត្តបានជម្រុញលើកកម្ពស់គំរូ ត្មាតប៉ើយ ហើយផ្តល់ជាយោបល់ថែមទៀតថា វាគួរតែត្រូវបានចម្លងយកទៅអនុវត្តន៍នៅជម្រកសត្វព្រៃផ្សេងទៀតក្នុងខេត្ត។

សហគមន៍ត្មាតប៉ើយបានចែករម្លែកបទសពិសោធន៍របស់ខ្លួនជាមួយភូមិដទៃទៀតក្នុងដែនជម្រកសត្វព្រៃ គូលេនព្រហ្មទេព និងជាមួយខេត្តផ្សេងទៀតក្នុងប្រទេសកម្ពុជាផងដែរ។ តំណាងមកពីភូមិចំនួនប្រាំក្នុងរង្វង់ដែនជម្រកសត្វព្រៃនេះបានធ្វើទស្សនកិច្ចនៅត្មាតប៉ើយ ដើម្បីរៀនសូត្រពីជោគជ័យការងារអភិរក្សរបស់សហគមន៍នេះ។ លើសពីនោះ តំណាងមកពីភូមិផ្សេងក្រៅដែនជម្រកសត្វព្រៃបានមកធ្វើទស្សនកិច្ចស្វែងយល់អំពីគំរូក្នុងការ អនុវត្តដែនទ្រនាប់សហគមន៍ ផែនការប្រើប្រាស់ដីសហគមន៍ និងកម្មវិធីទេសចរណ៍ធម្មជាតិក្នុងមូលដ្ឋាន។ បច្ចុប្បន្ន មានភូមិចំនួន ៩ ដែលបានចម្លងតាមសកម្មភាពផែនការប្រើប្រាស់ដីធ្លីរបស់ត្មាតប៉ើយ ហើយភូមិ ៧ ផ្សេងទៀត បានចម្លងធ្វើតាមផ្នែក



ឯទៀតនៃសកម្មភាពទេសចរណ៍ធម្មជាតិដែរ។

សមាជិកជាច្រើននាក់របស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្នោតប៉ើយ ធៀន ក្រសាំង បានក្លាយខ្លួនជាអ្នកបណ្តុះបណ្តាលដល់សហគមន៍ផ្សេងទៀត ដូចជាភូមិដងផ្លាត និងភូមិព្រៃវែងជាដើម។ បទពិសោធន៍នេះបានជួយពង្រឹងបន្ថែមដល់តម្លៃ និងតម្រូវការឲ្យមានការចែករំលែកចំណេះតៗគ្នា ដោយតំណាងសហគមន៍ដែលទទួលបានការបណ្តុះបណ្តាល បានសម្តែងទំនោរចង់ឲ្យមានគំរូការផ្លាស់ប្តូរចំណេះដឹងរវាងសហគមន៍បែបនេះតទៅទៀត។ មានតំណាងសហគមន៍មួយចំនួនដែលបានចូលរួម បាននិយាយថា ការផ្លាស់ប្តូរព័ត៌មានរវាងគ្នាទៅវិញទៅមកមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកៀរគរការគាំទ្រ កសាងការទុកចិត្តគ្នា និងការចម្លងគំរូយកទៅអនុវត្តន៍។

ឧទាហរណ៍ជាក់លាក់មួយអំពីការចម្លងគំរូរបស់ត្នោតប៉ើយ គឺភូមិដងផ្លាត ដែលនៅទីនោះ សហគមន៍បានបង្កើត "ភោជនីយដ្ឋានសត្វត្នោត" ដែលនៅទីនោះ អ្នកទេសចរអាចស្នាក់ក្នុងតង់សាហ្វារី ដើម្បីមើលសត្វត្នោតកម្រ ក្នុងជម្រកធម្មជាតិរបស់វា។ គម្រោងមួយនេះ ក៏បានច្របាច់បញ្ចូលផងដែរនូវការតាមដានមើលសត្វកម្រដទៃទៀត រួមមានសត្វទោច និងទាព្រៃស្លាបសជាដើម។

## ដៃគូ

- អង្គការអភិរក្សសត្វព្រៃ WCS ជួយគាំទ្រដល់ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ ក្នុងការគ្រប់គ្រង ដែនជម្រកសត្វព្រៃ គូលេនព្រហ្មទេព ផ្តល់ប្រឹក្សាដល់រដ្ឋាភិបាល និងជួយក្នុងការអភិវឌ្ឍនីតិវិធីនិង គម្រោងអភិរក្សធនធានធម្មជាតិនិងការពារសត្វព្រៃ។
- ក្រសួងបរិស្ថាន និង អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សរបស់កម្ពុជាជាអ្នកគ្រង់គ្រងដែន ជម្រកសត្វព្រៃគូលេនព្រហ្មទេព និងអនុវត្តន៍សកម្មភាពគម្រោង។
- មជ្ឈមណ្ឌល សំ វាសនា សម្រាប់កិច្ចអភិរក្ស ប្រើការនាំភ្ញៀវមើលសត្វស្លាប ដើម្បីរកចំណូលដែលគេអាចយកមកទ្រទ្រង់ដល់សកម្មភាពអភិរក្ស និងជួយកសាងសមត្ថភាពដល់អ្នកសហគមន៍ ឲ្យចេះកែលម្អសេវាកម្មទេសចររបស់ពួកគេឲ្យកាន់តែប្រសើរថែមទៀត។
- ក្រុមប្រឹក្សាឃុំនិងអាជ្ញាធរភូមិ ជួយដល់គណៈកម្មការត្នោតប៉ើយ ឲ្យទទួលបាននូវការគាំទ្រពីសំណាក់ អ្នកភូមិ និងក្នុងរៀបចំកិច្ចប្រជុំភូមិ។ ក្រុមប្រឹក្សាឃុំនិងអាជ្ញាធរភូមិ ក៏ជួយជ្រោមជ្រែងគណៈកម្មការនេះផងដែរ ក្នុងការអនុវត្តបទបញ្ញត្តិនានាទាក់ទិននឹងការអភិរក្សក្នុងសហគមន៍។



## ឯកសារយោងបន្ថែមទៀត៖


- Mollman, S. 2007. 'Birding For a Cause in Cambodia,' *TIME*, Week of December 1, 2008.
- Svadlenak-Gomez, K., Clements, T., Foley, C., Kazakov, N. ,Lewis, D., Miquelle, D., and Stenhouse, R. 2007. *Paying for Results: WCS experience with direct incentives for conservation*. USAID and WCS. http://sanrem.cals.vt.edu/1010/WCS_DirectPaymentsForConservation.pdf
- Clements, T., John, A., Nielsen, K., An, D., Tan, S., and Milner-Gulland, E.J. 2009. Payments for biodiversity conservation in the context of weak institutions: Comparison of three programs from Cambodia. Ecological Economics 69 (2010), pp. 1283–1291. http://www.zoo.cam.ac.uk/zoostaff/csg/Clements%20et%20al.%202010%20PES%20Ecol%20Econ.pdf












Equator Initiative
Environment and Energy Group
United Nations Development Programme (UNDP)
304 East 45th Street, 6th Floor
New York, NY 10017
Tel: +1 646 781 4023
www.equatorinitiative.org


EQUATOR INITIATIVE

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) គឺជាបណ្តាញអភិវឌ្ឍន៍ពិភពលោកនៃអង្គការសហប្រជាជាតិ ដែលធ្វើការតស៊ូមតិ ដើម្បីឲ្យមានការកែប្រែ និងផ្សារភ្ជាប់ប្រទេសនានាជាមួយចំណេះដឹង, បទពិសោធន៍ និងធនធាន ដើម្បីជួយធ្វើឲ្យប្រជាពលរដ្ឋរស់នៅប្រសើរជាងមុន។

កិច្ចផ្តួចផ្តើមអេក្វាទ័រ នាំមកចូលរួមជាមួយគ្នា៖ អ.ស.ប, រដ្ឋាភិបាល, សង្គមស៊ីវិល, ក្រុមហ៊ុនជំនួញ, និងអង្គការមហាជន ដើម្បី ឲ្យស្គាល់ និងជម្រុញដំណោះស្រាយអភិវឌ្ឍន៍ដោយចីរភាពនៅមូលដ្ឋាន សម្រាប់ប្រជាពលរដ្ឋ ធម្មជាតិ និងសហគមន៍ ដែលមានភាពធន់ទ្រាំ។


©2012 by Equator Initiative
All rights reserved